# គំនូរព្រះមាល័យទេសនា[១]

## ១- ព័ត៌មានទូទៅ

ពាក្យថា ព្រះមាល័យទេសនា ហាក់បីដូចជាពាក្យថ្មីមួយដែលយើងពុំសូវបានឮ ឬពុំសូវចាប់អារម្មណ៍ពីមុនមក។ ប៉ុន្តែនៅទសវត្សរ៍ឆ្នាំ៦០គេស្គាល់ពាក្យនេះច្រើនតាមរយៈពិធីទេសន៍មហាជាតក៍។[២] ចំពោះឈ្មោះគំនូរ ព្រះមាល័យទេសនា ទៀតសោតក៏ហៅខុសគ្នាតាមតំបន់នីមួយៗ ជាក់ស្តែងនៅខេត្តសៀមរាបគេហៅថា គំនូរព្រះចូឡាមណីចេតិយ ព្រោះមានព្រះចូឡាមណីចេតិយនៅចំកណ្តាលផ្ទាំងគំនូរលម្អដោយពណ៌មាស ចួនកាលទឹបមាសដើម្បីពន្ទេចរូបព្រះចេតិយឱ្យកាន់តែច្បាស់និងល្អវិចិត្រទ្វេឡើង(រូបលេខ១)។ នៅតំបន់ដទៃទៀតដូចជាខេត្តកំពត ព្រៃវែង កណ្តាល យើងឃើញគេចារនៅលើគំនូរហៅខុសគ្នាគឺ៖ ព្រះមាល័យ មាល័យទេសនា ព្រះមាល័យស្ថានសួគ៌ ព្រះមាល័យទេសនា។



រូបលេខ១ ព្រះមាល័យកំពុងសួរព្រះឥន្រ្ទ

---

[១] ខ្ញុំដាក់ចំណងជើងដូច្នេះព្រោះតាងឱ្យគ្រប់ទិដ្ឋភាពក្នុងគំនូរ ម្យ៉ាងដាក់តាមលំនាំសៀវភៅនិងចារឹកឈ្មោះគំនូរ ហើយយើងនិយាយខ្ទីពីប្រវត្តិសិល្បៈ និងតួអង្គ។ ពុំបានពិភាក្សាវែងឆ្ងាយទៅលើលក្ខណៈសម្គាល់រូបនីមួយៗ ការវិវត្តសិល្បៈឡើយ។

[២] ស្រង់ពីធម្មទេសនាព្រះមហាសង្ឃរាជ ជួន ណាត សម្តែងក្នុងពិធីទេសនាមហាជាតក៍។

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

ទោះបីជាមានពាក្យហៅខុសគ្នាយ៉ាងណាក៏ដោយ ក៏ទិដ្ឋភាពទូទៅគំនូរតាមតំបន់ទាំងនោះសុទ្ធតែរៀបរាប់ពីដំណើរព្រះមាល័យក្នុងឥរិយាបថគង់សន្ទនាជាមួយទេវតាក្នុងបរិវេណព្រះចូឡាមណីចេតិយនាឋានតាវតឹង្សៗ បើយើងពិនិត្យតាមគម្ពីរព្រះត្រៃបិដកនោះយើងឃើញថាគ្មានព្រះសូត្រណាមួយនិយាយពីព្រះនាមព្រះថេរអង្គនេះឡើយៗ តែគេជឿថារឿងនេះតែងក្រោយព្រះពុទ្ធបរិនិព្វាននៅប្រទេសស្រីលង្កា ជារឿងរ៉ាវរបស់ព្រះថេរមួយអង្គព្រះនាម មាល័យ ជាអ្នកស្រុកកម្ពោជគ្រាម[៣] តែងនិមន្តបិណ្ឌបាត្រនៅក្នុងទីជនបទឈ្មោះ រោហនជនបទ[៤] ហើយហោះទៅកោះមាល័យជាកោះសំបូរដើមខ្លឹមចន្ទន៍ក្រហមទើបគេហៅលោកថា ព្រះមាល័យៗ ព្រះមាល័យជាអ្នកមានរិទ្ធានុភាពខ្លាំងពូកែលោកតែងហោះទៅឋាននរក ឋានសួគ៌ដើម្បីប្រាប់ដំណឹងដល់មនុស្សឋានកណ្ដាលឱ្យខំធ្វើបុណ្យកុសលៗ ហេតុនេះបានជាគេប្រដូចលោកនឹងព្រះមោគ្គលានជាអគ្គសាវ័កឆ្វេងសម័យពុទ្ធកាលៗ លក្ខណអស្ចារ្យអ្នកកោះលង្កាថ្វាយព្រះនាមមួយទៀតថា ព្រះមាល័យទេវថេរៗ ដំណើររឿងព្រះមាល័យទេវថេរមានបរិយាយក្នុងគម្ពីរ មាលេយ្យសូត្រ ជាភាសាបាលីតែងនៅប្រទេសភូមាក្នុងពុទ្ធសតវត្សរ៍ទី១៦-១៨ ផ្សាយចូលមកសុខោទ័យតាមរយៈឡាននាៅពុទ្ធសតវត្សរ៍ទី១៩-២០ៗ[៥] ប៉ុន្តែយើងមិនដឹងពីកាលប្បវត្តិរឿងព្រះមាល័យផ្សាយចូលមកស្រុកខ្មែរនៅសម័យណាក៏មិនប្រាកដ តែយើងមានសាស្ត្រាព្រះមាល័យជាច្រើនច្បាប់ ក្នុងនោះសាស្ត្រាព្រះមហាលេយ្យទិព្វថេរតែមួយគត់ដែលប្រាប់កាលបរិច្ឆេទចម្លងនៅពុទ្ធសករាជ២៤៥៦៩(រូបលេខ២)ៗ



រូបលេខ២ ប្រភព៖ Internet Archive

[៣] ច្បាប់ខ្លះសរសេរថា កន្ទោជនបទ ៗ

[៤] ច្បាប់ខ្លះសរសេរថា លោហជនបទៗ

[៥] សូមអាន៖finearts.go.th/thailandmuseum/view/24678-พระมาลัย-ทำไมจึงถือพัด-หรือตาลปัตร

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

## ២- លក្ខណៈទូទៅនៃគំនូរ

យើងសង្កេតឃើញថាគំនូរ ព្រះមាល័យទេសនា បានបង្ហាញពីឋានតាវត្តឹង្សត្រង់ទីប្រតិស្ឋានព្រះចូឡាមណីចេតិយមានទេវតាជាច្រើនអង្គ កំពុងមកប្រជុំគ្នានៅខាងមុខព្រះចេតិយដើម្បីចុះមកថ្វាយបង្គំ បូជាទៀន ធូប ភ្ញីផ្កា និងស្តាប់ព្រះមាល័យសន្ទនាជាមួយព្រះឥន្ទ្រដែលមានសម្បុរខៀវកំពុងអង្គុយប្រណម្យចំពោះមុខព្រះមាល័យ ជាប្រធាននៅក្នុងទីនោះ។ អ្វីដែលគួរឱ្យយើងចាប់អារម្មណ៍ទៅទៀតនោះគឺឥរិយាបថរបស់ព្រះមាល័យគង់ព្រះហស្តម្ខាងកាន់តាលបណ្ណ(ផ្ចិតស្ទឹកត្នោត) ហើយព្រះហស្តម្ខាងទៀតចង្អុលឡើងលើ ប៉ុន្តែពុំមែនជាការសម្តែងធម៌ឡើយគឺចង្អុលទៅរកទេវបុត្រមួយអង្គហៀបនឹងចុះ។ ទេវបុត្រដែលព្រះមាល័យចង្អុលនោះជាព្រះពោធិសត្វអរិយមេត្តេយ្យមានពន្លឺជុំវិញខ្លួនដែលខុសប្លែកពីទេវតាដទៃ(រូបលេខ៣,៤,៥,៦)។



រូបលេខ៣ ប្រភព៖(?)

អត្ថបទដោយ៖ រីម ទិត្យបញ្ញា



រូបលេខ២៨ ប្រភព៖(?)



រូបលេខ២៩




រូបលេខ២៦

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

## ៣- លក្ខណៈដោយឡែកនៃគំនូរ

ដោយស្ថិតនៅតំបន់ផ្សេងគ្នាមនុស្សមានចំណេះដឹង គំនិត ការយល់ឃើញ ការនិយមផ្សេងៗគ្នា។ ក្នុងបរិបទនេះគំនូរដែលនៅតំបន់ខុសគ្នាមិនអាចដូចគ្នាទាំងស្រុងបាទេ ផ្ទៃគំនូរត្រូវគូរសង្ខេបដំណើររឿងជាច្រើនអន្លើ ចំនួនរូបទេវតាក្នុងគំនូរតិចៗ គំនូរខ្លះកាត់យកត្រឹមព្រះឥន្ទ្រសន្ទនាជាមួយព្រះមាល័យនិងទេវតា(រូបលេខ២៧)។ គំនូរខ្លះទៀតកាត់យកត្រឹមដំណើរព្រះមាល័យគង់សន្ទនាជាមួយព្រះអរិយមេត្តេយ្យតែពីរអង្គ(រូបលេខ២៨)។



រូបលេខ២៧



រូបលេខ២៨ ប្រភព៖ ហៃ គីមហុង

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

ចំពោះការបង្ហាញកាយវិការព្រះមាល័យក៏ខុសគ្នាដូចជា៖ ព្រះហស្តម្ខាងចង្អុលទៅលើ ម្ខាងទៀតកាន់ផ្ចិត(រូបលេខ៩)។ ព្រះហស្តម្ខាងចង្អុលទៅលើ ម្ខាងទៀតមិនកាន់អ្វីទាំងអស់(រូបលេខ១០)។ ព្រះហស្តម្ខាងដាក់ត្រួតលើភ្នែន ហើយព្រះហស្តម្ខាងទៀតកាន់ផ្ចិត(រូបលេខ១១)។ ព្រះហស្តម្ខាងដាក់លើព្រះឧរុ(ភ្លៅ)បង្ហាញពីការសង្រួម ព្រះហស្តម្ខាងទៀតចង្អុល(រូបលេខ១២)។ ព្រះហស្តម្ខាងបង្ហាញពីឥរិយាបថសម្តែងធម៌(រូបលេខ១៣)។ ព្រះហស្តទាំងពីរដាក់លើព្រះឧរុ(ភ្លៅ)បង្ហាញពីការសង្រួម(រូបលេខ១៤)។


រូបលេខ៩


រូបលេខ១០


រូបលេខ១១


រូបលេខ១២


រូបលេខ១៣


រូបលេខ១៤

អត្ថបទដោយ៖ រឹម ទិត្យបញ្ញា

# ឯកសារពិគ្រោះ

គង់ ឈួយ

១៩៦៥, ព្រះមាល័យទេសនា, បាត់ដំបង

Internet Archive

មហាលេយ្យទិព្វថេរ (ក-កះ, ខ-ខិ) : Free Borrow & Streaming : Internet Archive

Khmer Manuscript Heritage

BUDA - Buddhist Digital Archives (bdrc.io)

Thailand museum

finearts.go.th/thailandmuseum/view/24678-พระมาลัย-ทำไมจึงถือพัด-หรือตาลปัตร

vajirayana

พระมาลัยคำหลวง คำนำ (vajirayana.org)

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយៈ រឹម ទិត្យបញ្ញា